# សេចក្តីប្រកាសព័ត៌មាន
# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងប្រារព្ធ ខួប ២០ ឆ្នាំ

*រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២*

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងខែតុលា ឆ្នាំ២០០២។

ចាប់តាំងពីបង្កើតមក ម.ស.ម.ក បានធ្វើចូលរួមចំណែកដើម្បីឱ្យប្រទេសកម្ពុជាមិនមានអំពើហិង្សា ដែលសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យជាគោលដៅសំខាន់ និងស្របតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩១ ("កិច្ចព្រមព្រៀងទីក្រុងប៉ារីស") ដែលបានកំណត់ផ្លូវសម្រាប់ការកសាងសន្តិភាព និងប្រជាធិបតេយ្យនៅកម្ពុជាហើយនៅខែតុលានេះក៏ជាខួបលើកទី ៣១ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសផងដែរ។ ម.ស.ម.ក ខិតខំដើម្បីសម្រេចបាននូវចក្ខុវិស័យចង់ឃើញប្រទេសកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាជនទាំងអស់អាចទទួលបានសិទ្ធិជាមូលដ្ឋានអនុលោមតាមគោលការណ៍នីតិរដ្ឋ គ្មាននិទណ្ឌភាព ហើយទទួលបានសិទ្ធិស្មើភាពគ្នា គ្មានការរើសអើង មានសិទ្ធិអំណាចក្នុងការចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការប្រជាធិបតេយ្យ និងអាចចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព ។ ម.ស.ម.ក បានអនុវត្តការងារដ៏សំខាន់ក្នុងការលើកកម្ពស់ និងការពារគុណតម្លៃ និងសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងជំរុញឱ្យកម្ពុជាសម្រេចបាននូវកាតព្វកិច្ចសិទ្ធិមនុស្សដែលមាននៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាបានផ្តល់សច្ចាប័ន ។

ក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនេះ ម.ស.ម.ក បានខិតខំប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហាសិទ្ធិមនុស្សជាច្រើន ហើយបានផ្តល់ការគាំទ្រជូនប្រជាពលរដ្ឋជាច្រើននៅទូទាំងប្រទេស រួមទាំងអ្នកការពារសិទ្ធិមនុស្ស សកម្មជន អ្នកសារព័ត៌មាន ស្ត្រី អ្នកស្រលាញ់ភេទដូចគ្នា និងសហគមន៍ដែលខ្វះខាត ដើម្បីទាមទារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តាមរយៈការអប់រំអំពីសិទ្ធិមនុស្ស ការពង្រឹងអំណាច និងការតស៊ូមតិ។ ម.ស.ម.ក ក៏បានជួយជនរងគ្រោះជាច្រើនពីការរំលោភសិទ្ធិមនុស្សដើម្បីស្វែងរកយុត្តិធម៌និងផ្តល់ជំនួយជាច្រើន រួមទាំងជំនួយផ្នែកច្បាប់ និងជំនួយដែលពាក់ព័ន្ធ ដែលនាំឱ្យមានការរួមចំណែកដោយផ្ទាល់ និងយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។ តាមរយៈការងារស្នូលរបស់ ម.ស.ម.កក្នុងការការពារសេរីភាពជាមូលដ្ឋាន កំណែទម្រង់ប្រព័ន្ធតុលាការនិងនីតិបញ្ញត្តិ សមភាពនិងការមិនរើសអើង ធុរកិច្ច និងសិទ្ធិមនុស្ស ការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ដូចជាការស្រាវជ្រាវ ការតស៊ូមតិ និងគោលនយោបាយ ម.ស.ម.ក សង្ឃឹមថានឹងចូលរួមចំណែកក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិ

រដ្ឋសម្រាប់ពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជា។

នៅខែតុលា ឆ្នាំ២០២២ ម.ស.ម.ក នឹងប្រារព្ធខួប ២០ឆ្នាំដោយបង្ហាញពីការងាររបស់ខ្លួនក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ តាមរយៈ៖

- ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ ម.ស.ម.ក នឹងចេញផ្សាយកម្រងវីដេអូ ដែលលើកឡើងនូវសាររបស់អ្នកទទួលផលដែលបង្ហាញចំណាប់អារម្មណ៍អំពី ម.ស.ម.ក ព្រមទាំងវីដេអូអំពី ម.ស.ម.ក ក្នុងខួប ២០ឆ្នាំនេះផងដែរ។
- នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ម.ស.ម.ក នឹងរៀបចំកម្មវិធី ពិព័រណ៍ការងាររបស់ ម.ស.ម .ក ដោយមានការផ្តល់ជូនសៀវភៅ និងឯកសារបោះពុម្ពផ្សាយនានាដោយពុំគិតថ្លៃព្រមទាំងមានកម្មវិធីសម្រាប់អ្នកចូលរួមឆ្លើយសំណួរអំពីសិទ្ធិមនុស្សដើម្បីទទួលបានរង្វាន់វត្ថុអនុស្សាវរីយ៍ផងដែរ។

***លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក មានប្រសាសន៍ថា៖*** *"ការចូលរួមចំណែករបស់ ម.ស.ម.ក ក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា ក្នុងរយៈពេលពីទស្សវត្សចុងក្រោយនេះ អាចធ្វើទៅបាន ដោយសារការគាំទ្រដ៏មានតម្លៃពីដៃគូ និងម្ចាស់ជំនួយក្នុងស្រុក និងអន្តរជាតិជាច្រើន និងការចូលរួមយ៉ាងសកម្មរបស់សាធារណជនក្នុងការកសាងសង្គមមួយឱ្យកាន់តែមានការគោរពសិទ្ធិមនុស្ស។ ម្ភៃឆ្នាំមកនេះ ម.ស.ម.ក នៅតែប្តេជ្ញាដូចថ្ងៃដំបូងក្នុងការសម្រេចឱ្យបាននូវបេសកកម្មរបស់ខ្លួន ហើយនឹងបន្តការងារដ៏សំខាន់របស់ខ្លួន ដើម្បីធានាថាការគោរពសិទ្ធិមនុស្សនឹងក្លាយជាការពិតសម្រាប់ទាំងអស់គ្នាក្នុងប្រទេសកម្ពុជា។"*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក តាមរយៈទូរស័ព្ទ៖ + ៨៥៥ (០) ១១ ៩៤៣ ២១៣ ឬអ៊ីម៉ែល chaksopheap@cchrcambodia.org។**

**- ចប់ -**

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជា

សមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្ដាញប្រឆាំងទារុណកម្ម អេស អូ អេស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្ដូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្ដូរសង្គម នៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសប៊េន ប្រទេសអូស្ត្រាលី៕